AMBASSADE
DE FRANCE
AU CAMBODGE
*Liberté*
*Égalité*
*Fraternité*

INSTITUT FRANÇAIS
Cambodge

# Et j’ai chanté, chanté !

## ការប្រកួតចម្រៀងជាភាសាបារាំង

*ស្ថានទូតបារាំងនៅកម្ពុជា និងវិទ្យាស្ថានបារាំងនៅកម្ពុជា*

## <u>លក្ខខណ្ឌនៃការចូលរួម និងការចុះឈ្មោះ</u>

វិទ្យាស្ថានបារាំងនៅកម្ពុជា នឹងរៀបចំកម្មវិធីប្រកួតចម្រៀងភាសាបារាំង នៅក្នុងក្របខណ្ឌនៃការអបអរសាទរកម្មវិធីហ្វ្រង់កូហ្វូនី ក្នុងខែមីនា ឆ្នាំ២០២៥។

### មាត្រា ១ ៖ លក្ខខណ្ឌចូលរួម

បេក្ខជនដែលមាន**អាយុពី១0ឆ្នាំឡើងទៅ** និងដែលមានទីលំនៅក្នុងប្រទេសកម្ពុជា អាចដាក់ពាក្យចូលរួមក្នុងការប្រកួតប្រជែងនេះបាន។

បេក្ខជនអាចច្រៀងតែម្នាក់ឯងក៏បាន ឬជាក្រុមក៏បាន។

- **ជំហានដែលត្រូវធ្វើ ៖**

១) បេក្ខជនឬក្រុមនីមួយៗ ត្រូវបំពេញទម្រង់បែបបទចុះឈ្មោះ Google Form ដែលអាចទាញយកបានតាមរយៈកូដ QR ឬតាមតំណភ្ជាប់នេះ ៖ https://forms.gle/1ZsBbMRdmPrs28486

២) បេក្ខជនឬក្រុមនីមួយៗ ត្រូវផ្ញើសំឡេងច្រៀងដែលខ្លួន បានថតនេះក្រោមទម្រង់ mp3 ដោយត្រូវប្រុងប្រយ័ត្នលើគុណភាពនៃការថតសំឡេង ពីព្រោះថាការជ្រើសរើសជំណាក់កាលទីមួយផ្អែកលើសំឡេងដែលថតនេះ។ ឈ្មោះរបស់ឯកសារសំឡេងនេះ ត្រូវមានដាក់ឈ្មោះបេក្ខជន (ឬឈ្មោះក្រុម) និងចំណងជើងបទចម្រៀង (ឧទាហរណ៍៖ នាម.គោត្តនាម_ចំណងជើងបទចម្រៀង)។ បេក្ខជនត្រូវផ្ញើសំឡេងច្រៀងដែលបានថតទៅកាន់កញ្ញា Clothilde SAUTREL តាមរយៈអាសយដ្ឋាន coopfr.ifc@gmail.com **យ៉ាងយូរបំផុតត្រឹមថ្ងៃទី១ ខែមីនា ឆ្នាំ២០២៥។**

ដើម្បីចៀសវាងរាល់ការលំបាកក្នុងការផ្ញើសំឡេងច្រៀងថតក្រោមទម្រង់mp3 ដែលមានទំហំធំមកកាន់ពួកយើង បេក្ខជនអាចប្រើប្រព័ន្ធចែកចាយឯកសារអនឡាញ (dropbox, Wetransfer, Smash.fr…)បាន។ សូមទាក់ទងមកយើងខ្ញុំ ក្នុងករណីដែលមានបញ្ហា។

### មាត្រា ២ ៖ ការជ្រើសរើសបេក្ខជន

បេក្ខជនដែលត្រូវបានជ្រើសរើសដោយវិទ្យាស្ថានបារាំង នឹងត្រូវបានអញ្ជើញចូលរួមប្រកួតវគ្គផ្តាច់ព្រ័ត្រ នៅ **ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៥** នៅលើឆាករបស់វិទ្យាស្ថានបារាំងនៅកម្ពុជា។

នៅថ្ងៃទី១៩ ខែមីនា បេក្ខជនដែលចូលរួមវគ្គផ្តាច់ព្រ័ត្រត្រូវច្រៀងបទចម្រៀង ដែលខ្លួនបានផ្ញើមកពេលចុះឈ្មោះ។ បេក្ខជនដែលទទួលបានជ័យលាភីនៅវគ្គផ្តាច់ព្រ័ត្រ នឹងទទួលបានរង្វាន់ទៅតាមចំណាត់ថ្នាក់។

### មាត្រា ៣ ៖ សិទ្ធិក្នុងការផ្សព្វផ្សាយរូបភាព

នៅក្នុងការប្រកួតនេះ យើងខ្ញុំសូមរក្សាសិទ្ធិក្នុងការថតរូបភាព និងវីដេអូរបស់បេក្ខជនទាំងអស់ ដែលនឹងអាចត្រូវបានយកទៅផ្សព្វផ្សាយនៅលើបណ្តាញសង្គម និងលើគេហទំព័ររបស់វិទ្យាស្ថានបារាំងនៅកម្ពុជា និងដៃគូសហការរបស់ខ្លួន។

ការផ្ញើទម្រង់បែបបទចុះឈ្មោះមកកាន់ពួកយើង បញ្ជាក់ថាបេក្ខជនទាំងអស់យល់ព្រមចំពោះលក្ខខណ្ឌខាងលើនេះ។

### មាត្រា ៤ ៖ កាលបរិច្ឆេទសំខាន់ៗ

- រហូតដល់ថ្ងៃទី១ ខែមីនា ឆ្នាំ២០២៥ ៖ ទទួលបេក្ខភាព
- ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៥ ៖ ប្រកាសឈ្មោះបេក្ខជនដែលមានសិទ្ធិចូលរួមប្រកួតវគ្គផ្តាច់ព្រ័ត្រ
- ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៥ ៖ ការហាត់សម និងការប្រកួតផ្តាច់ព្រ័ត្រ

### មាត្រា ៥ ៖ លក្ខខណ្ឌនៃការជ្រើសរើស

លក្ខខណ្ឌនៃការជ្រើសរើសក្នុងដំណាក់កាលទី១ រួមមាន៖

- គុណភាពសម្លេង
- ការបកស្រាយបទចម្រៀង
- គំនិតច្នៃប្រឌិតក្នុងការជ្រើសរើសបទចម្រៀង ឬក្នុងការបកស្រាយបទចម្រៀង
- គុណភាពក្នុងការបញ្ចេញសំឡេងជាភាសាបារាំង

ការរៀបចំតុបតែងខ្លួន ក៏ជាកត្តាមួយក្នុងការជ្រើសរើសបេក្ខជននៅវគ្គផ្តាច់ព្រ័ត្រផងដែរ។

**មាត្រា ៦ ៖ គណៈកម្មការ**

ការសម្រេចចិត្តរបស់គណៈកម្មការនៅវគ្គផ្តាច់ព្រ័ត្រ គឺធ្វើឡើងដោយឆន្ទានុសិទ្ធិ និងបិទផ្លូវតវ៉ា។

**មាត្រា ៧ ៖ វគ្គផ្តាច់ព្រ័ត្រនៅរាជធានីភ្នំពេញ**

ចំណាយលើការធ្វើដំណើរមកកាន់រាជធានីភ្នំពេញ ការស្នាក់នៅ និងអាហារ ជាបន្ទុករបស់បេក្ខជនផ្ទាល់។

បេក្ខជនដែលត្រូវបានជ្រើសរើសឱ្យចូលរួមវគ្គផ្តាច់ព្រ័ត្រ ត្រូវតែចូលរួមក្នុងការហាត់សមដែលនឹងប្រព្រឹត្តទៅនៅវិទ្យាស្ថានបារាំងនៅកម្ពុជានាព្រឹកថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៥ ជាកំហិត។

បេក្ខជនដែលជាអនីតិជន ត្រូវតែមានអាណាព្យាបាលនៅជាមួយតាំងពីពេលចាប់ផ្តើមរហូតដល់ចប់កម្មវិធី។

## ឧបសម្ព័ន្ធ៖ ជំនួយស្មារតីក្នុងការជ្រើសរើសបទចម្រៀង

បេក្ខជនអាចជ្រើសរើសបទចម្រៀងចេញពីក្នុងបញ្ជីខាងក្រោមបាន៖

១/ **បទចម្រៀងបារាំងថ្មីៗ** ៖ Angèle, Pomme, Clara Luciani, Juliette Armanet, Lous and the Yakuza, Chilla, Stromae, Camelia Jordana, Slimane, Diam´s, Vitaa, BB Brunes, Pierre de Maere, Eddy de Pretto, Hoshi, Vianney, Charlotte Cardin, L'Impératrice ។ល។

២/ **បទចម្រៀងបារាំងពិរោះៗល្បីៗ** ៖ M (Matthieu Chedid), Téléphone, Daniel Belavoine, Cœur de Pirate, Céline Dion (en français), Bénabar, Patrick Bruel, Louise Attaque, Tryo, Kali, Kyo, Vanessa Paradis, France Gall, Amadou & Mariam, Françoise Hardy, Véronique Sanson, Michel Sardou, Francis Cabrel, Bobby Lapointe, MC Solaar, Zazie, Alain Souchon, et Laurent Voulzy ។ល។

៣/ **បទចម្រៀងមរតកជាភាសាបារាំង** ៖ Joe Dassin, Jacques Brel, Barbara, Charles Aznavour, Serge Reggiani, Léo Ferré, Georges Brassens, Jean Ferrat, Claude Nougaro, Juliette Gréco, Yves Montand, Charles Trénet, Edith Piaf, Les Rita Mitsouko ។ល។

៤/ **ការតាក់តែងបទថ្មី៖** យើងខ្ញុំលើកទឹកចិត្តបេក្ខជនឲ្យបង្កើតបទចម្រៀងថ្មីដោយខ្លួនឯង!

តារាចម្រៀងដូចដែលបានរាយនាមខាងលើ បានច្រៀងចម្រៀងជាច្រើនដែលលោកអ្នកអាចយកមកច្រៀងក្នុងការប្រកួតនេះបាន។ ដើម្បីទទួលបានគំនិតច្រើនជាងនេះក្នុងការជ្រើសរើសស្ទីលបទភ្លេងដែលលោកអ្នក

ស្រឡាញ់ចូលចិត្ត សូមកុំស្ទាក់ស្ទើរក្នុងការស្វែងរកមើលកម្រងបទចម្រៀងនៅលើអ៊ីនធើណេត (Spotify, Youtube, Deezer -ល-) ។

ការច្នៃប្រឌិតថ្មី ក៏នឹងធ្វើឲ្យបេក្ខជនទទួលបានពិន្ទុដែរ ហេតុនេះហើយ សូមកុំស្ទាក់ស្ទើរក្នុងការស្វែងរកបទចម្រៀងរបស់តារាចម្រៀងមួយរូប ដែលនឹងអាចធ្វើឲ្យគណៈកម្មការភ្ញាក់ផ្អើល!

សូមប្រុងប្រយ័ត្ន មិនត្រូវយកបទខាងក្រោមនេះមកច្រៀងឡើយ៖

- *On écrit sur les murs*, Kids United
- *Dernière danse*, Indila
- *L'oiseau et l'enfant*, Marie Myriam (et autres interprètes)